**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

៚៚៚✱៚៚៚

# កិច្ចព្រមព្រៀងរវាង
# រោងចក្រ អែនឌើសេន អ៊ិនជាស្ទ្រី ឯ.ក ជាមួយនិង
# កម្មករនិយោជិតទាំងអស់ ស្តីអំពីការព្យួរកិច្ចសន្យាការងារ និងនីតិវិធីទូទាត់

ដោយមើលឃើញថារោងចក្រខ្វះការបញ្ជាទិញ ដែលធ្វើអោយរោងចក្រមិនមានការងារអោយកម្មករនិយោជិតធ្វើគ្រប់គ្រាន់ កម្មករនិយោជិតទាំងអស់ ដែលតំណាងដោយសហជីព និងប្រតិភូបុគ្គលិក ឯកភាពគ្នាជាមួយរោងចក្រ ក្នុងការព្យួរកិច្ចសន្យាការងារ និងក្នុងការទូទាត់ប្រាក់ឧបត្ថម្ភដូចខាងក្រោម៖

១- ត្រូវព្យួរកិច្ចសន្យាការងារចាប់ពីថ្ងៃទី១... ខែសីហា ឆ្នាំ២០២១ រហូតដល់ ថ្ងៃទី៣០ ខែកញ្ញា.. ឆ្នាំ២០២១។ សំរាប់អំឡុងពេលនៃការព្យួរនេះ កម្មករនិយោជិតមិនទទួលបានប្រាក់ឈ្នួលទេ ប៉ុន្តែរោងចក្រផ្តល់ប្រាក់ឧបត្ថម្ភចំនួន ៥០% នៃប្រាក់ឈ្នួលគោល ដល់កម្មករនិយោជិតម្នាក់ៗ ដោយផ្តល់ជូនតាមរយៈគណនេយ្យរបស់កម្មករនិយោជិត នៃធនាគារ អេស៊ីលីដា (Acleda), វីង (Wing) ឬបើកផ្ទាល់ជាសាច់ប្រាក់ (Cash) ដែលត្រូវផ្តល់ជូនដូចទៅនឹងកាលបរិច្ឆេទ នៃការបើកប្រាក់ឈ្នួលទាំងពីរលើកក្នុងខែនីមួយៗផងដែរ។

២- រោងចក្រនឹងរៀបចំសំណើសុំព្យួរកិច្ចសន្យាការងារ របស់កម្មករនិយោជិត និងឯកសារដែលពាក់ព័ន្ធផ្សេងទៀត ដើម្បីគោរពជូនទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល ដើម្បីទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារ ក៏ដូចជាដើម្បីបងប្អូនកម្មករនិយោជិតអាចទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល។

៣- សំរាប់ប្រាក់រង្វាន់ការងារទៀងទាត់ ប្រាក់ឧត្ថម្ភការធ្វើដំណើរនិងស្នាក់នៅ និងប្រាក់រង្វាន់ផ្ទាល់ខ្លួនរបស់កម្មករនិយោជិត ដែលមានការព្យួរកិច្ចសន្យាការងារភាគខ្លះនៃខែនោះ រោងចក្រនឹងផ្តល់ជូនតាមអត្រាសមាមាត្រនឹងចំនួនថ្ងៃដែលបានធ្វើការងារជាក់ស្តែង (ពោលគឺមិនផ្តល់ជូនចំពោះអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនោះទេ)។

**<u>បញ្ជាក់៖</u>** កិច្ចព្រមព្រៀងនេះ មានប្រសិទ្ធិភាពចំពោះកម្មករនិយោជិតទាំងអស់របស់រោងចក្រ អែនឌើសេន អ៊ិនជាស្ទ្រី ឯ.ក ជាមួយនិងនិយោជកនៃរោងចក្រ ចាប់ពីពេល

ចុះហត្ថលេខានេះតទៅ។

ធ្វើនៅខេត្តកណ្ដាល ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១

**តំណាងភាគីកម្មករនិយោជិត**
**ថ្នាក់ដឹកនាំសហជីព និង ប្រតិភូបុគ្គលិក**

**តំណាងភាគីរោងចក្រ**
**នាយកក្រុមហ៊ុន**

Administration
ANDERSEN INDUSTRIES CO., LTD.

Lim Soon Seng